
អបអរថ្ងៃបុណ្យណូអែល
Marry Christmas
ព្រះប្រទានកាដូពិសេស គឺជីវិតអស់កល្ប ដល់មនុស្សគ្រប់ៗគ្នា

# អត្ថន័យថ្ងៃបុណ្យណូអែល

## តើបុណ្យណូអែលគឺជាអ្វី ?



បុណ្យណូអែល ធ្វើឡើងដើម្បីរំលឹកពីប្រវត្តិកំណើតរបស់ព្រះយេស៊ូវដែលទ្រង់បានចាប់កំណើតជាមនុស្សក្នុងគោលបំណងសង្គ្រោះមនុស្សលើផែនដីនេះអោយមានទំនាក់ទំនងល្អជាមួយព្រះវរបិតា និងរួចពីអំពើបាប ព្រះយេស៊ូវជាភាសាក្រិចមានន័យថា "ព្រះសង្គ្រោះ"។ ព្រះទ្រង់ដែលយាងមកនោះគឺអង្គព្រះយេស៊ូវគ្រីស្ទ។

# ព្រះអង្គបង្កើតទេវតា

ព្រះជាម្ចាស់បានបង្កើតទេវតាជាច្រើន ដើម្បីថ្វាយបង្គ
និងបំរើទ្រង់។ ក្នុងចំណោមពួកទេវតា មានទេវតា
មួយអង្គបានបបួលទេវតា មួយភាគបីនៃទេវតាក្នុង
ស្ថានសួគ៌ អោយក្បត់ព្រះ ហើយព្រះបានទំលាក់ពួកវា
មកពីនគរស្ថានសួគ៌។ ចាប់ពីពេលនោះមក វាបានក្លាយ
ជាសត្រូវរបស់ព្រះជាម្ចាស់ ហើយកិច្ចការរបស់វានៅ
ផែនដី គឺលួចសំលាប់ ហើយបំផ្លាញជីវិតមនុស្ស។
វាកុហកបោកប្រាស់អោយមនុស្សគ្រប់រូបធ្វើ
ដំណើរទៅរកសេចក្តីស្លាប់។



អារក្សសាតាំង


ព្រះអង្គបង្កើតភពផែនដី
និងរបស់ទាំងអស់
ព្រះអង្គបានបង្កើតមនុស្សនិង
អ្វីៗទាំងអស់នៅលើផែនដី
យ៉ាងល្អប្រពៃ ហើយពេញ
ដោយសេចក្តីសុខសាន្ត
អំណរសប្បាយ គ្មាន
ភាពអាក្រក់ និងអំពើបាប។

# ការធ្លាក់ក្នុងអំពើបាបរបស់មនុស្ស

រាប់ពាន់ឆ្នាំ សាតាំងបាននាំ
មនុស្សអោយវង្វេងនៅក្នុង
អំពើបាបក្រោយពេលដែល
មនុស្សជ្រើសរើសមិនស្តាប់
បង្គាប់ព្រះជាម្ចាស់ ហើយ
ដើរតាមផ្លូវរបស់វា
ដែលនាំទៅរកអំពើបាប
និងសេចក្តីស្លាប់
ចាប់តាំងពីពេល
នោះមក។



ហេតុនេះបានជាមនុស្សដំណារ
ក្រោយកើតមកជាប់នូវ
អំពើបាប។ ហើយមាន
សាសនាជាច្រើនបាន
ព្យាយាមបង្រៀនមនុស្ស
អោយជៀសពីអំពើបាប
ប៉ុន្តែពួកគេមិនអាច។
គ្មាននរណាម្នាក់អាច
ធ្វើបានក្រៅពីព្រះ
ជាម្ចាស់ឡើយ។

# ព្យាការីអេសាយថ្លែងពីកំណើតព្រះយេស៊ូវគ្រីស្ទ



ប៉ុន្តែព្រះទ្រង់បានស្រលាញ់មនុស្សលោក
ដែលទ្រង់បានបង្កើត ហើយទ្រង់បានរៀបចំផែនការ
នៃសេចក្តីសង្គ្រោះ។ ព្រះជាម្ចាស់មានព្រះបន្ទូលទាយទុក
មុនជាង ៧០០ឆ្នាំមុន គ-ស តាមរយៈព្យាការីអេសាយថា
"មើល! ស្ត្រីព្រហ្មចារីយ៍ នឹងមានផ្ទៃពោះ នាងនឹង
សំរាលបានបុត្រ មួយដែលគេនឹងថ្វាយព្រះនាមថា
"អេម៉ាញូអែល" ប្រែថាព្រះគង់ជាមួយយើង"
ហើយហេតុការណ៍នោះបានកើតឡើងពិតប្រាកដមែន។



# កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ

នេះជាផែនការរបស់ព្រះជាម្ចាស់
អោយព្រះយេស៊ូវគ្រីស្ទមកយកកំណើត
ជាមនុស្សតាមរយៈស្ត្រីព្រហ្មចារីយ៍
ឈ្មោះនាងម៉ារា ត្រូវជាគូរដណ្តឹង
របស់លោកយ៉ូសែប។
ការចាប់កំណើតនេះ
កើតមកពីអំណាច
ព្រះវិញ្ញាណបរិសុទ្ធ។

# ព្រះយេស៊ូវប្រសូត្រក្នុងក្រោលសត្វ

បន្ទាប់មកនាងមានផ្ទៃពោះ ហើយពួកគេទាំងពីរបាននាំគ្នាទៅចុះឈ្មោះជំរឿនប្រជាជនតាមបញ្ជារបស់ស្តេចហេរ៉ូតនៃចក្រភពរ៉ូម ក្នុងភូមិបេថ្លេហិម។នៅពេលទៅដល់ភូមិបេថ្លេហិម ស្រាប់តែនាងម៉ារាឈឺពោះរៀបនឹងសំរាលកូន ស្របពេលបណ្តាជនមកពីគ្រប់ទីកន្លែងដែរ ធ្វើអោយគ្មានបន្ទប់ជួល និងកន្លែងស្ងប់ស្ងាត់សំរាប់សំរាលកូន ។ ម្ចាស់ផ្ទះសំណាក់បានអោយពួកគេសំរាលកូននៅក្រោលសត្វ ហើយបុត្រ នោះបានប្រសូត្រមកឈ្មោះថា យេស៊ូវ តាមរយៈបញ្ជារបស់ព្រះជាម្ចាស់ដែលប្រាប់ យ៉ូសែបតាមរយៈទេវតា ។





# ការអបអរចំពោះកំណើតរបស់ព្រះយេស៊ូវ

នៅថ្ងៃកំណើតព្រះអង្គ ទេវតាដ៏ច្រើននៅស្ថានសួគ៌
ធ្វើការអបអរដោយច្រៀង សរសើរដល់បុត្រតូចនេះ។
មានអ្នកប្រាជ្ញបីនាក់មកពីទិសខាងកើតនាំ មាស ជ័រល្វីងទេស
"ជារបស់មានតំលៃ" គ្រឿងក្រអូបមកថ្វាយទ្រង់
ដោយសេចក្ដីអំណរ។ នេះជាមូលហេតុ
ដែលចាប់ផ្ដើមនូវប្រពៃណីមួយ
នៅថ្ងៃណូអែលគឺជាការជូនកាដូ។



# សាតាំងព្យាយាមបំផ្លាញផែនការព្រះ



អារក្សសាតាំងជាខ្មាំងសត្រូវរបស់ផងព្រះ
វាបានព្យាយាមបំផ្លាញផែនការសង្គ្រោះរបស់ព្រះ
ដោយប្រើអំណាចស្តេចរ៉ូម ដោយបញ្ជូនទាហាន
អោយទៅសំលាប់ទារកទាំងអស់ដែលមាន
អាយុបីឆ្នាំចុះក្រោម។ ព្រះជាម្ចាស់បាន
បញ្ជូនទេវតាមកប្រាប់ លោកយ៉ូសែប
តាមរយៈសុបិន្តនិម្មិតអោយនាំកូន
និងប្រពន្ធរត់គេចខ្លួន។

# ព្រះយេស៊ូវបំពេញភារកិច្ចនៅលើផែនដី

កាលព្រះយេស៊ូវមានព្រះជន្ម៣០ឆ្នាំ ទ្រង់ចាប់ផ្ដើមបង្រៀនមនុស្សអោយស្គាល់ និងយល់អំពីនគរព្រះ ព្រមទាំងធ្វើការអស្ចារ្យជាច្រើន ដូចជាប្រោសជំងឺ បណ្ដេញវិញ្ញាណអាក្រក់ ជួយមនុស្សខ្វាក់អោយមើលឃើញ និងមនុស្សខ្វិនអោយដើរបាន។



# ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ



មុនពេលព្រះយេស៊ូវ
សុគតនៅលើឈើឆ្កាង
ផែនដីទាំងមូលប្រែទៅជា
ងងឹតសូន្យចាប់តាំងពីពេល
ថ្ងៃត្រង់ រហូតដល់ម៉ោងបី
រសៀល។ ហើយទ្រង់ក៏ត្រូវ
បានជាប់ឆ្កាង ដើម្បីលោះអំពើបាប
មនុស្សទាំងអស់ និងដើម្បីអោយយើង
មានទំនាក់ទំនងជាមួយព្រះវរបិតាដូចមុនវិញ។
ស្របតាមបទទំនាយ លោកហោរាអេសាយបានទាយទុក។

# ព្រះយេស៊ូវរស់ពីសុគតឡើងវិញ



ព្រះយេស៊ូវគ្រីស្ទមិនបានសុគតរហូតឡើយ។ មើល៎! បីថ្ងៃក្រោយមកទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ។ ទ្រង់បានបង្ហាញអង្គទ្រង់អោយសាវ័ក និងមនុស្ស ឯទៀតឃើញ ដើម្បីប្រាប់ដល់យើងថាព្រះអង្គមានអំណាចលើអំពើបាបលើសេចក្តីស្លាប់ និងមានអំណាចក្នុងការរំដោះយើងអោយរួចពីកណ្តាប់ដៃ អារក្សសាតាំង បន្ទាប់មកព្រះវរបិតាបានលើកអង្គទ្រង់ឡើងទៅឯនគរស្ថានសួគ៌វិញ។

ព្រះយេស៊ូវជាព្រះមានព្រះជន្មរស់នៅសព្វថ្ងៃនេះ

# អត្ថន័យដើមឈើណូអែល




ដើមឈើណូអែលមានពណ៌បៃតង
ជានិច្ចដែលតំណាងអោយបុណ្យណូអែល
មានអត្ថន័យសំដៅទៅលើជីវិតអស់កល្បជានិច្ច
ដែលព្រះជាម្ចាស់ ប្រទានអោយដល់មនុស្ស
គ្រប់ៗគ្នាគ្រាន់តែព្រមទទួលជឿព្រះយេស៊ូវគ្រីស្ទ។

ព្រះយេស៊ូវគ្រីស្ទជាកាដូពិសេស សំរាប់ជួយសង្គ្រោះអស់អ្នកដែលទទួលទ្រង់

## សេចក្ដីអធិដ្ឋានយាងព្រះអង្គសង្គ្រោះ

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ កូនសូមយាងព្រះអង្គគង់ និងធ្វើជាម្ចាស់ក្នុងជីវិតរបស់កូន ដ្បិតព្រះអង្គមានសេចក្ដីមេត្តាករុណាដល់ រូបកូនរាល់គ្នា។ កូនសូមថ្វាយជីវិតទៅព្រះអង្គ មានតែព្រះអង្គទេដែលសង្គ្រោះកូនអោយរួចពីអំពើបាប សូមព្រះអង្គទទួលសេចក្ដីអធិស្ឋានរបស់កូនផង។ កូនសូមអរព្រះគុណដែលទ្រង់បានសង្គ្រោះកូនក្នុងព្រះនាម ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ

អាម៉ែន!

## ការទទួលស្គាល់កំណើតថ្មី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ................ បានទទួលព្រះយេស៊ូវគ្រីស្ទជាព្រះអង្គម្ចាស់សង្គ្រោះរបស់ខ្ញុំ។ ខ្ញុំបានជឿថាព្រះយេស៊ូវបានសុគតដើម្បីអោយខ្ញុំមានជីវិតថ្មី។ ខ្ញុំអះអាងថា "ទ្រង់ជាម្ចាស់លើជីវិតខ្ញុំ" ។

ថ្ងៃ.....ខែ.....ឆ្នាំ ២០....

ស្នាមមេដៃ ឬហត្ថលេខា




ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបាន
ជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមកដើម្បីអោយ
អស់អ្នកណាដែលជឿលើបុត្រាមានជីវិតអស់កល្បជានិច្ច
គឺមិនអោយគេវិនាសឡើយ។ " យ៉ូហាន ៣:១៦ "

២០០៩-២០១០

រក្សាសិទ្ធិ
FCOP

ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ :០២៣ ៨៦ ៦២ ០៩